# អ្វីទាំងអស់ដែលអ្នកត្រូវដឹងក្នុងការចុះឈ្មោះបោះឆ្នោត

អ្នកត្រូវតែចុះឈ្មោះបោះឆ្នោតជ្រើសរើសសភាក្នុងប្រទេសញ៉ូស៊ីឡេន ។ បើអ្នកចង់បានដំណឹងបន្ថែម សូមទូរសព្ទមកលេខ 0800 ENROL NOW, (0800 36 76 56) ឬមកមើល វិបសាយ www.elections.org.nz ។

យ៉ាងហោចណាស់ប្រទេសញ៉ូស៊ីឡេនត្រូវរៀបចំការបោះឆ្នោតជាសាកលម្តងក្នុងរយៈពេលបីឆ្នាំ ដើម្បីជ្រើសរើស រដ្ឋសភា និងរដ្ឋាភិបាលថ្មី ។ ប្រព័ន្ធការបោះឆ្នោតហៅថាអឹមអឹមភី (Mix Member Proportional) អនុញ្ញាតឱយអ្នកចុះឈ្មោះបោះឆ្នោត ជ្រើសរើសយកពីរសម្លេង ។ សម្លេងទីមួយ ជ្រើសរើសយកគណបក្សណាដែលអ្នកចូលចិត្តជាងគេ ។ សម្លេងទីពីរ ជ្រើសរើសយកបេក្ខជនណាដែលអ្នកចង់ឱយជាប់ជាសមាជិកសភាក្នុងមណ្ឌលរបស់អ្នក ។

មណ្ឌលណាដែលអ្នកត្រូវបោះឆ្នោត សម្រេចទៅតាមអាសយដ្ឋានរបស់អ្នក ។ បញ្ជីចុះឈ្មោះបោះឆ្នោតមាន : បញ្ជីសាកល និង បញ្ជីមៅរី ។ មណ្ឌលនិមួយៗមានបញ្ជីឈ្មោះរបស់អ្នកដែលចុះឈ្មោះបោះឆ្នោតទាំងអស់ ។ បើអ្នកអាយុ១៨ឆ្នាំ ឬលើសពី១៨ ឆ្នាំ អ្នកត្រូវតែចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ បើអ្នកអាយុ១៧ឆ្នាំ អ្នកអាចចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតជាបណ្តោះអាសន្ន ។ ពេលបានចុះឈ្មោះហើយ អ្នកត្រូវឱយដំណឹងមកយើងភ្លាមបើសិនជាមានការកែប្រែ ។ អ្នកកាន់បញ្ជីបោះឆ្នោតធ្វើការឱយ New Zealand Post Ltd ដែលជាអ្នករក្សាទុកបញ្ជីចុះឈ្មោះបោះឆ្នោតនេះ ។

## មាតិការ

**ការចុះឈ្មោះបោះឆ្នោត** 3
តើខ្ញុំមានគុណសម្បត្តិចុះឈ្មោះឬទេ? 3
ហេតុអ្វីបានជាខ្ញុំត្រូវចុះឈ្មោះ? 3
តើខ្ញុំត្រូវចុះឈ្មោះយ៉ាងដូចម្តេច? 3
តើខ្ញុំបានក្រដាសសុំចុះឈ្មោះពីកន្លែងណា? 3
តើខ្ញុំអាចចុះឈ្មោះឬកែប្រែដំណឹងតាមប្រព័ន្ធអ៊ិនធឺណិតបានឬទេ? 4
តើខ្ញុំអាចចុះឈ្មោះមុនអាយុ១៨បានឬទេ? 4
ខ្ញុំជាអ្នកពិការ-តើខ្ញុំអាចរកគេជួយចុះឈ្មោះបានឬទេ? 4
ខ្ញុំមានគ្រួសារនិងមិត្តនៅបរទេស តើខ្ញុំអាចចុះឈ្មោះឱយគេបានឬទេ? 4
អ្វីទៅបញ្ជីបោះឆ្នោត ដែលមិនបោះពុម្ពផ្សាយ? 5
តើគេធ្វើដូចម្តេចដល់ក្រដាសចុះឈ្មោះខ្ញុំ បន្ទាប់ពីខ្ញុំបានធ្វើត្រឡប់ទៅវិញនោះ? 5
តើដំណឹងអ្វីខ្លះដែលខ្ញុំត្រូវប្រាប់គេ? 5

**ការចុះឈ្មោះក្នុងបញ្ជីមៅរី** 7
ការជ្រើសរើសចុះឈ្មោះក្នុងបញ្ជីមៅរី? 7
ខ្ញុំជាសាសន៍ញ៉ូស៊ីឡេនមៅរី តើខ្ញុំជ្រើសរើសយកបញ្ជីមួយណា? 7
ចុះបើខ្ញុំជាសាសន៍មៅរីចុះឈ្មោះលើកដំបូង? 7
តើញឹកញយទេ ដែលគេឱយជ្រើសរើសចុះឈ្មោះក្នុងបញ្ជីមៅរី? 7
ខ្ញុំសាសន៍កោះប៉ាស៊ីហ្វិក ប៉ូលីនេសៀន តើខ្ញុំអាចចុះឈ្មោះក្នុងបញ្ជីមៅរីបានឬទេ? 7

**បញ្ជីបោះឆ្នោត** 7
អ្វីទៅជាបញ្ជីបោះឆ្នោតសភា? 7
តើខ្ញុំអាចរកមើលបញ្ជីបោះឆ្នោតនៅកន្លែងណា? 7
តើគេយកដំណឹងចុះឈ្មោះបោះឆ្នោតទៅធ្វើអ្វី? 8
**ឱយយើងដឹងភ្លាមបើអ្នកមានការកែប្រែអំពីដំណឹងអ្នកក្នុងការចុះឈ្មោះ?** 8
តើខ្ញុំត្រូវធ្វើដូចម្តេចបើខ្ញុំផ្លាស់ប្តូរអាសយដ្ឋាន? 8
តើខ្ញុំត្រូវធ្វើដូចម្តេចបើខ្ញុំផ្លាស់ប្តូរឈ្មោះឬប្តូរមុខងារ? 8
តើយ៉ាងដូចម្តេចបើខ្ញុំភ្លេចប្រាប់ពីការផ្លាស់ប្តូរដំណឹងរបស់ខ្ញុំ? 8

**យុទ្ធការចុះឈ្មោះឱយបានត្រឹមត្រូវ** 9
អ្វីជាយុទ្ធការចុះឈ្មោះឱយបានត្រឹមត្រូវ? 9
តើខ្ញុំត្រូវធ្វើដូចម្តេចពេលមានយុទ្ធការចុះឈ្មោះឱយបានត្រឹមត្រូវ? 9
យ៉ាងដូចម្តេចបើខ្ញុំមិនបានធ្វើក្រដាសកែប្រែចុះឈ្មោះត្រឡប់ទៅវិញពេលយុទ្ធការចុះឈ្មោះ? 9
ចុះបើខ្ញុំទទួលក្រដាសកែប្រែចុះឈ្មោះរបស់អ្នកដទៃដែលឈប់រស់នៅអាសយដ្ឋាននេះហើយនោះ? 9
ចុះបើខ្ញុំមិនបានទទួលក្រដាសកែប្រែចុះឈ្មោះនោះ? 9

**ព្រំដែនមណ្ឌលបោះឆ្នោត** 9
ខ្ញុំមិនដែលផ្លាស់ផ្ទះផង ហេតុអ្វីបានជាគេដាក់ខ្ញុំនៅមណ្ឌលបោះឆ្នោតផ្សេងទៀត? 9

**ការបោះឆ្នោតដទៃទៀត** 10
អ្វីជាការបោះឆ្នោតសភាពិសេស? 10
អ្វីជាការបោះឆ្នោតតាមតំបន់? 10
តើខ្ញុំមានសិទ្ធិបោះឆ្នោតប្រជាមតិផ្តើមដោយប្រជាពលរដ្ឋ និង/ឬ ប្រជាមតិផ្តើមដោយរដ្ឋាភិបាលឬទេ? 10

**ដំណឹងបន្ថែម** 10
តើខ្ញុំអាចបានដំណឹងនេះជាភាសាផ្សេងទៀតឬទេ? 10

# សេចក្តីផ្តើម

# ការចុះឈ្មោះបោះឆ្នោត

## តើខ្ញុំមានគុណសម្បត្តិចុះឈ្មោះឬទេ?

អ្នកមានគុណសម្បត្តិនិងត្រូវចុះឈ្មោះធ្វើតាមច្បាប់បើ :

- អ្នកជាពលរដ្ឋញ៉ូស៊ីឡែន ឬជាអ្នកមានសិទ្ធិរស់នៅជាអចិន្ត្រៃ និង
- អ្នកមានអាយុ១៨ឆ្នាំឬលើសពី១៨ឆ្នាំ និង
- អ្នកបានរស់នៅក្នុងប្រទេសញ៉ូស៊ីឡែនជាប់ បានលើសពីមួយឆ្នាំ និង
- អ្នកមិនបានត្រូវគេដកសិទ្ធិ។

## តើគេដកសិទ្ធិខ្ញុំយ៉ាងដូចម្តេច?

អ្នកមិនអាចចុះឈ្មោះបោះឆ្នោតបានបើ :

- អ្នកជាពលរដ្ឋញ៉ូស៊ីឡែន ដែលរស់នៅក្រៅប្រទេសដែលមិនបានវិលមកវិញក្នុងរយៈពេល៣ឆ្នាំចុងក្រោយ ។
- អ្នកមានសិទ្ធិរស់នៅញ៉ូស៊ីឡែន តែអ្នកបានរស់នៅក្រៅប្រទេសញ៉ូស៊ីឡែន ដែលមិនបានវិលមកវិញក្នុងរយៈពេល ១២ខែ ចុងក្រោយ ។

(កំណត់សំគាល់ : លើកលេងពីច្បាប់ខាងលើទាំងពីរឧទាហរណ៏ អ្នករដ្ឋការ ឬទាហានដែលនៅក្រៅប្រទេសញ៉ូស៊ីឡែន ព្រមទាំងគ្រួសាររបស់អ្នកទាំងនោះ ) មានមូលហេតុផ្សេងទៀតដែលគេហាមមិនឱយបោះឆ្នោតដែលប៉ះពាល់ដល់ប្រជាជនមួយចំនួនតូច ។ អ្នកកាន់បញ្ជីបោះឆ្នោតអាចប្រាប់អោយដឹងនូវមូលហេតុនេះ ។ បើអ្នកមានសំនួរ ទាក់ទងទៅនឹងមូលហេតុហាមផ្សេងទៀតនេះ សូមទូរសព្ទ មកលេខ 0800 ENROL NOW, (0800 36 76 56) ឬមកមើលវិបសាយរបស់យើង www.elections.org.nz

## ហេតុអ្វីបានជាខ្ញុំត្រូវចុះឈ្មោះ?

អ្នកត្រូវតែចុះឈ្មោះបោះឆ្នោត បើអ្នកមានគុណសម្បត្តិទាំងនោះ ។ បានចុះឈ្មោះ ទើបមានឱកាសឱយអ្នក បានបោះឆ្នោត ដើម្បីបញ្ចេញមតិ អំពីបេក្ខជនណា ឬគណបក្សណាដែលអ្នកចង់ជ្រើសរើសធ្វើជាសភាប្រទេសញ៉ូស៊ីឡែន ក្នុងពេលបោះឆ្នោតជាសាកល ។ អ្នកក៏អាចបោះឆ្នោតជ្រើសរើស ក្រុមអាជ្ញាធរតាមតំបន់ និងជ្រើសរើសគណៈមណ្ឌលផ្នែកសុខាភិបាល និងជ្រើសរើសប្រជាមតិឬការស្ទង់មតិនិមួយៗដែរ។

## តើខ្ញុំត្រូវចុះឈ្មោះយ៉ាងដូចម្តេច?

អ្នកគ្រាន់តែបំពេញក្រដាសឈ្មោះហៅថា" ក្រដាសសុំចុះឈ្មោះបោះឆ្នោត" ។ អ្នកត្រូវតែសុំចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត សូម្បីតែអ្នកមិនចង់បោះឆ្នោតក៏ដោយ ។ បើអ្នកជាសាសន៏ញ៉ូស៊ីឡែនមៅរី ឬជាប់សាច់ឈាមជាញ៉ូស៊ីឡែនមៅរីចង់ចុះឈ្មោះជាដំបូង អ្នកអាចប្រើក្រដាស សុំចុះឈ្មោះនោះ ហើយជ្រើសរើសបញ្ជីណាដែលអ្នកចង់ចុះឈ្មោះ ។ អ្នកអាចជ្រើសរើសបញ្ជីមៅរី ឬបញ្ជីសាកល ។

## តើខ្ញុំបានក្រដាសសុំចុះឈ្មោះពីកន្លែងណា?

- ដោយបំពេញនិងផ្ញើប័ណ្ណផ្ជាប់នៅចុងអត្ថបទនេះមកយើង, យើងនឹងផ្ញើក្រដាសសុំចុះឈ្មោះឱយ ។
- សុំដោយឥតគិតថ្លៃ ពីប៉ុស្តិ៍អូសហ្វីស ។
- សូមទូរសព្ទដោយឥតគិតថ្លៃ មកលេខ 0800 ENROLNOW, (0800 36 76 56) យើងនឹងផ្ញើក្រដាសសុំចុះឈ្មោះឱយ ។
- សុំឬបោះពុម្ពចេញពី វិបសាយរបស់យើង www.elections.org.nz ។

ក្រោយពីអ្នកបំពេញក្រដាសសុំចុះឈ្មោះហើយ អ្នកអាចប្រគល់ក្រដាសនេះនៅប៉ុស្តអូសហ្វិស ឬផ្ញើមកយើង (ដោយមិនចាំបាច់បិតតែម) :

Freepost 2Enrol
Electoral Enrolment Centre
P O Box 190
Wellington 6015

## តើខ្ញុំអាចចុះឈ្មោះឬកែប្រែដំណឹងតាមប្រព័ន្ធអ៊ិនធឺណិតបានឬទេ?

ធ្វើបាន គ្រាន់តែចូលទៅមើលក្នុងវិបសាយរបស់យើង www.elections.org.nz ហើយចុច "Check your enrolment details or enrolment online." ហើយធ្វើតាមការបង្ហាញព្រមទាំងបំពេញការចុះឈ្មោះ។ អ្នកអាចដោនឡូតនិងបោះពុម្ពក្រដាសបំពេញចុះឈ្មោះនោះ រួចចុះហត្ថលេខា និងផ្ញើមកយើងដើម្បីបញ្ចប់កិច្ច ។ ម្យ៉ាង ទៀតបើអ្នកបំពេញហើយអ្នកអាចចុចផ្ញើតាមប្រព័ន្ធអ៊ិនធឺណិត យើងនឹងផ្ញើក្រដាសចុះឈ្មោះរបស់អ្នកមកវិញ ដើម្បីឱ្យអ្នកពិនិត្យ,ចុះហត្ថលេខានិងផ្ញើត្រឡប់មកយើងវិញ ។ អ្នកក៏អាចពិនិត្យអំពីការចុះឈ្មោះ online តាមប្រព័ន្ធអ៊ិនធឺណិតនៅក្នុង វិបសាយរបស់យើងបានដែរ ។

## តើខ្ញុំអាចចុះឈ្មោះមុនអាយុ១៨បានឬទេ?

ធ្វើបាន ពេលអ្នកអាយុ១៧ឆ្នាំក្លាម អ្នកអាច "ចុះឈ្មោះជាបណ្តោះអាសន្ន" ដោយបំពេញក្រដាសចុះឈ្មោះនេះ ។ ពេលណាអ្នកគ្រប់អាយុ១៨ ឈ្មោះអ្នកនឹងចុះចូលក្នុងបញ្ជីជាស្វ័យប្រវត្តិ ។

ដំណឹងបន្ថែមមាននៅក្នុងកូនសៀវភៅរបស់យើងឈ្មោះ "Enrolling to vote before you're 18" ដែលមាននៅប៉ុស្តអូសហ្វិស ឬសូមទូរសព្ទមកលេខ 0800 ENROLNOW, (0800 36 76 56) យើងនឹងផ្ញើឱ្យអ្នកមួយក្បាល ។

## ខ្ញុំជាអ្នកពិការ . តើខ្ញុំអាចរកគេជួយចុះឈ្មោះបានឬទេ?

បើអ្នកពិការរាងកាយ ត្រូវការគេជួយបំពេញនិងផ្ញើក្រដាសចុះឈ្មោះ អ្នកអាចធ្វើដូច្នេះ

- អ្នកអាចឱ្យអ្នកកាន់បញ្ជីបោះឆ្នោតជួយបំពេញ រួចឱ្យគេចុះហត្ថលេខា ។

  គេត្រូវសរសេរឱ្យច្បាស់នៅក្បែរហត្ថលេខានោះថា "Elector Physically Disabled – signed by their direction."
- ឬ អ្នកអាចឱ្យអំណាចទៅមេធាវីឱ្យគេជួយបំពេញ រួចឱ្យគេចុះហត្ថលេខា ។

  គេត្រូវសរសេរឱ្យច្បាស់នៅក្បែរហត្ថលេខានោះថា "Elector Physically Disabled – Power of Attorney."

បើសមាជិកណាមួយក្នុងគ្រួសារអ្នកមានពិការខាងខួរក្បាល អ្នកអាចជួយបំពេញឱ្យបាន ។ សូមទូរសព្ទមកលេខ 0800 ENROL NOW, (0800 36 76 56) ដើម្បីរកដំណើងបន្ថែម ។

## ខ្ញុំមានគ្រួសារនិងមិត្តនៅបរទេស តើខ្ញុំអាចចុះឈ្មោះឱ្យគេបានឬទេ?

ធ្វើបាន បើសិនអ្នកនោះនៅមានសិទ្ធិបោះឆ្នោត អ្នកអាចជួយបំពេញចុះឈ្មោះឱ្យគេបាន ។ អ្នកអាចធ្វើដូច្នេះ :

- បើអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត អ្នកអាចបំពេញក្រដាសចុះឈ្មោះឱ្យអ្នកនោះបាន រួចអ្នកចុះហត្ថលេខា ។ អ្នកត្រូវសរសេរឱ្យច្បាស់នៅលើក្រដាសនៅក្បែរ

ហត្ថលេខាអ្នកនោះថា “Elector Overseas – signed by their direction.”

- ឬបើអ្នកទទួលអំណាចមេធាវីអំពីអ្នកនោះ អ្នកអាចបំពេញក្រដាសចុះឈ្មោះនិងចុះហត្ថលេខាអ្នកលើក្រដាសចុះឈ្មោះអ្នកនោះ ។ អ្នកត្រូវសរសេរឱយច្បាស់លើក្រដាស នៅក្បែរហត្ថលេខាអ្នកនោះថា “Elector Overseas – Power of Attorney .”

## អ្វីទៅបញ្ជីបោះឆ្នោតដែលមិនបោះពុម្ពផ្សាយ?

បើអ្នកជឿថាដំណឹងរបស់អ្នកចុះក្នុងបញ្ជីដែលគេបោះផ្សាយអាចគំរាមកំហែងដល់សន្តិសុខផ្ទាល់របស់អ្នក, អ្នកអាចសុំដំណឹងរបស់អ្នកខ្លះ កុំឱយគេចុះផ្សាយក្នុងបញ្ជីបាន។ អ្នកត្រូវសុំ ថែមផ្សេងទៀតក្នុងការមិនឱយគេបោះពុម្ពផ្សាយព្រមទាំងបង្ហាញនូវភស្តុតាងអំពីសភាពការផ្ទាល់របស់អ្នកដូចជា ការបញ្ជាចេញអំពីតុលាការ កុំឱយអ្នកទៅជួបឬទៅណា ដើម្បីការពារសន្តិសុខដល់អ្នកដ៏ទៃ ឬដោយអ្នកមានបណ្តឹង អំពីនគបាលជាដើម។

ដំណឹងបន្ថែមនិងក្រដាសសុំកុំឱយគេចុះផ្សាយក្នុងបញ្ជីមាន នៅក្នុងកូនសៀវភៅរបស់យើងឈ្មោះ
"Everything you need to know about unpublished electoral roll"
ដែលមាននៅប៉ុស្តអូសហ្វីស ឬសូមទូរសព្ទមកលេខ
0800 ENROL NOW, (0800 36 76 56)
យើងនឹងផ្ញើឱយអ្នកមួយក្បាល ។

## តើគេធ្វើដូចម្តេចដល់ក្រដាសចុះឈ្មោះខ្ញុំបន្ទាប់ពីខ្ញុំបានផ្ញើត្រឡប់ទៅវិញនោះ?

អ្នកកាន់បញ្ជីបោះឆ្នោតនឹងពិនិត្យមើលថា តើអ្នកបំពេញនោះត្រឹមត្រូវឬទេ ។ បើត្រឹមត្រូវហើយឈ្មោះអ្នកនឹងចុះនៅក្នុងបញ្ជីបោះឆ្នោតនៅមណ្ឌលដែលអ្នករស់នៅយ៉ាងហោចណាស់បានមួយខែចុងក្រោយ ។ យើងនឹងផ្ញើសំបុត្រអោយអ្នកដឹង ដើម្បីបញ្ជាក់អំពីការបានចុះឈ្មោះនេះ ។

## តើដំណឹងអ្វីខ្លះដែលខ្ញុំត្រូវប្រាប់គេ?

សូមឆ្លើយនូវសំនួរទាំងអស់នៅលើក្រដាសសុំចុះឈ្មោះ ដើម្បីឱយយើងចុះឈ្មោះអ្នកឱយបានត្រឹមត្រូវ ។ មានតែដំណឹងដែលមានសញ្ញាផ្កាយ ( * ) ប៉ុណ្ណោះដែលគេនឹងបោះពុម្ពផ្សាយក្នុងបញ្ជី ។

*YOUR FULL NAME : ឈ្មោះអ្នកពេញ :
យើងត្រូវការឈ្មោះដើម្បីពិនិត្យថាតើអ្នកបានចុះឈ្មោះត្រឹមត្រូវឬទេ ព្រមទាំងសំគាល់ ឈ្មោះអ្នកអំពីឈ្មោះអ្នកឯទៀតដែលមានឈ្មោះដូចគ្នាឬ ឈ្មោះស្រដៀងគ្នា ។

DATE OF BIRTH : ថ្ងៃកំណើត :
ថ្ងៃកំណើត បង្ហាញអ្នកកាន់បញ្ជីថាអ្នកមានអាយុចំណាស់អាចចុះឈ្មោះបាន ព្រមទាំងជួយសំគាល់ ពីអ្នកដែលមានឈ្មោះដូចគ្នាឬ ឈ្មោះស្រដៀងគ្នា ។

SIGNATURE AND DATE : ហត្ថលេខានិងថ្ងៃខែ :
បើអ្នកជាសាសន៍ញ៉ូស៊ីឡេនមេរី ឬជាប់សាច់ឈាមជាញ៉ូស៊ីឡេនមេរី, អ្នកត្រូវចុះហត្ថលេខានិងដាក់ថ្ងៃខែតែមួយកន្លែងប៉ុណ្ណោះ ។ គឺកន្លែងសំរាប់មេរី ឬក៏ កន្លែងសំរាប់សាកល **កុំចុះហត្ថលេខាទាំងពីរកន្លែង** ។ ជាការសំខាន់អ្នកត្រូវជ្រើសរើស ដោយប្រយ័ត្ន នូវបញ្ជីណាដែលអ្នកចង់ចុះឈ្មោះ។ អ្នកឯទៀត ត្រូវចុះហត្ថលេខានៅកន្លែងសាលក ។ បើអ្នកពិការ ឬ អ្នកនៅឯបរទេស គេអាចចុះហត្ថលេខាជំនួសអ្នក លើក្រដាសសុំចុះឈ្មោះនោះបាន ។

*RESIDENTIAL ADDRESS : អាស័យដ្ឋានរស់នៅ នេះជាអាស័យដ្ឋានផ្ទះរបស់អ្នក ។ លេខប្រអប់សំបុត្រនៅប៉ុស្តិ៍ ឬលេខចែកតាមជនបទ មិនគ្រប់គ្រាន់ក្នុងការរៀបរាប់អំពីអាស័យដ្ឋានរបស់អ្នកឡើយ ។ យើងត្រូវការអាស័យដ្ឋានលំនៅ របស់អ្នកពេញលេញ ដើម្បីឱយយើងចុះឈ្មោះអ្នក ត្រូវក្នុងមណ្ឌលដែលអ្នក "រស់នៅ " ។

អ្នក "រស់នៅ " នៅកន្លែងដែលអ្នកជ្រើសរើសជា លំនៅដ្ឋានរបស់អ្នក ដោយហេតុគ្រួសារឬញាតិឬដោយហេតុថាជាស្រុកខ្លួនឬ ដោយហេតុផ្ទាល់ខ្លួនក្តី ។ ដោយសារអ្នកជួនកាលមិនបាននៅផ្ទះជាប់ មិនមែនមានន័យថា អ្នកមិនរស់នៅទីកន្លែងនោះទេ ។ អ្នកដែលខានមិនបានរស់នៅផ្ទះដោយសារ កិច្ចការក្តី ឬដោយសារការរៀនសូត្រក្តី (ឬដោយសារ កិច្ចការ ឬការរៀនសូត្រ របស់ប្តីឬប្រពន្ធអ្នកក្តី ) ក៏មិនធ្វើឱយអ្នក មានឈ្មោះថាប្តូរកន្លែងរស់នៅដែរ ។ មូលហេតុសំខាន់ដែល សម្រេចថាកន្លែងណាជា កន្លែងអ្នករស់នៅនោះ គឺស្ថិតនៅលើការជ្រើសករើសកន្លែងនោះជាទីលំនៅដ្ឋានរបស់អ្នក ។

POSTAL ADDRESS : អាស័យដ្ឋានផ្ញើសំបុត្រ :
យើងត្រូវការអាស័យដ្ឋានផ្ញើសំបុត្របើអាស័យដ្ឋាននេះខុសអំពីអាស័យដ្ឋានរស់នៅ ។ យើងត្រូវការសរសេរទៅអ្នកបញ្ជាក់អំពីការសុំចុះឈ្មោះរបស់អ្នក ។

*OCCUPATION : មុខងារ :
ដំណឹងអំពីមុខងារនេះក៏ អាចជួយយើងដើម្បីសំគាល់អ្នកដែលមាន ឈ្មោះដូចគ្នា ។ ភាគច្រើន គេបោះពុម្ពមុខងារក្នុងបញ្ជី ជាពាក្យកាត់ ។

ARE YOU MAORI ? : តើអ្នកជាសាសន៍មៅរីឬ ?
មានតែសាសន៍ញូ៉សុីឡែនមៅរី ឬជាប់សាច់ឈាមជាញូ៉សុីឡែនមៅរី ប៉ុណ្ណោះដែលត្រូវជ្រើសរើសយករង្វង់ YES អ្នកឯទៀតត្រូវជ្រើសរើសយករង្វង់ NO.

PHONE NUMBERS : លេខទូរសព្ទ :
លេខទូរសព្ទត្រូវការព្រោះក្រែងយើងត្រូវការទាក់ទងទៅអ្នក ។

SKETCH MAP : គូសផែនទី :
បើអ្នករស់នៅអាស័យដ្ឋានដែលគ្មានលេខ យើងត្រូវការអ្នកគូសផែនទីបង្ហាញកន្លែងអ្នករស់នៅ ដើម្បីជួយយើងចុះឈ្មោះអ្នកឱយត្រូវតាមមណ្ឌលបោះឆ្នោត ។

HAVE YOU CHANGE YOUR ADDRESS RECENTLY ? តើអ្នកមានប្តូរអាស័យដ្ឋានក្នុងពេលថ្មីៗនេះដែរឬទេ?
បើអ្នករស់នៅអាស័យដ្ឋានសព្វថ្ងៃតិចជាងមួយខែ សូមអ្នកបំពេញនៅកន្លែងនេះ ។

NEW ZEALANDERS OVERSEAS : ពលរដ្ឋញូ៉សុីឡែននៅឯបរទេស :
អ្នកត្រូវបំពេញនៅកន្លែងនេះ បើអ្នកនៅឯបរទេស ។ សូមសរសេរប្រាប់ថា ពេលណាអ្នករស់នៅចុងក្រោយបង្អស់នៅញូ៉សុីឡែន, ពេលណាអ្នកទៅបរទេស និងអាស័យដ្ឋានរបស់អ្នកចុងក្រោយបង្អស់ ដែលអ្នករស់នៅយ៉ាងហោចណាស់ ក៏បានមួយខែមុនអ្នកទៅបរទេស ។

# ការចុះឈ្មោះក្នុងបញ្ជីមោរី

## ការជ្រើសរើសចុះឈ្មោះក្នុងបញ្ជីមោរី?

បើអ្នកសាសន៍ញូ៉ស៊ីឡែនមោរី ឬជាប់សាច់ឈាមជាញូ៉ស៊ីឡែនមោរី អ្នកអាចជ្រើសរើសចុះឈ្មោះនៅក្នុងបញ្ជីសាកលក៏បាន បញ្ជីមោរីក៏បាន ។

## ខ្ញុំជាសាសន៍ញូ៉ស៊ីឡែនមោរី តើខ្ញុំជ្រើសរើសយកបញ្ជីមួយណា?

ប្រាំឆ្នាំម្តង គេផ្ញើក្រដាសឱយជ្រើសរើសទៅគ្រប់អ្នកដែលបានចុះឈ្មោះដែលបានឆ្លើយថាខ្លួនជាអ្នកជាប់សាច់ឈាមញូ៉ស៊ីឡែនមោរី ។ ក្រដាសនេះសម្រាប់ប្រើ បើអ្នកចង់ជ្រើសរើសចុះឈ្មោះនៅក្នុងបញ្ជីមោរី ឬបញ្ជីសាកល ។ ការជ្រើសរើសនេះហៅថា ការធ្វើសកម្មភាពឱយជ្រើសរើសចុះឈ្មោះក្នុងបញ្ជីមោរី។

## ចុះបើខ្ញុំសាសន៍មោរីចុះឈ្មោះលើកដំបូង?

អ្នកអាចជ្រើសរើសយកបញ្ជីមួយណាដែលអ្នកចង់ចុះឈ្មោះ បើអ្នកជាសាសន៍ញូ៉ស៊ីឡែនមោរី ដោយចុះហត្ថលេខានៅកន្លែង ដែលគេតម្រូវនៅលើក្រដាសសុំចុះឈ្មោះនោះ ។ ពេលអ្នក សម្រាប់ជ្រើសរើសរួចហើយ អ្នកមិនអាចផ្លាស់ប្តូរបានទេ ទាល់តែដល់ពេល គេធ្វើសកម្មភាពឱយជ្រើសរើសចុះឈ្មោះក្នុងបញ្ជីមោរីជាលើកក្រោយទៀត។

## តើញឹកញយទេ ដែលគេឱយជ្រើសរើសចុះឈ្មោះក្នុងបញ្ជីមោរី?

គេឱយជ្រើសរើសចុះឈ្មោះក្នុងបញ្ជីមោរី ប្រាំឆ្នាំម្តង ធ្វើក្នុងរយៈពេលបួនខែ និងអនុញ្ញាតឱយអ្នកចុះឈ្មោះក្នុងបញ្ជីមោរី មានឱកាសពិនិត្យឡើងវិញ និងផ្លាស់ប្តូរការជ្រើសរើស បញ្ជីចុះឈ្មោះរបស់ខ្លួន ។

## ខ្ញុំសាសន៍កោះប៉ាស៊ីហ្វិក ប៉ូលីនេសៀន តើខ្ញុំអាចចុះឈ្មោះក្នុងបញ្ជីមោរីបានឬទេ?

មិនបានទេ គឺសម្រាប់តែ សាសន៍ញូ៉ស៊ីឡែនមោរី ឬជាប់សាច់ឈាមជាញូ៉ស៊ីឡែនមោរី ។ អ្នកកោះឃុកអាយឡិន និងអ្នកកោះប៉ាស៊ីហ្វិកឯទៀតដែលមាន គុណសម្បត្តិចុះឈ្មោះ ត្រូវចុះឈ្មោះក្នុងបញ្ជីសាកល។
ដំណឹងបន្ថែមមាននៅក្នុងកូនសៀវភៅរបស់យើងឈ្មោះ "Enrolling to vote as a New Zealand Maori"

# បញ្ជីបោះឆ្នោត

## អ្វីទៅជាបញ្ជីបោះឆ្នោតសភា?

បញ្ជី ជាសៀវភៅដែលរាយឈ្មោះ អ្នកបានចុះឈ្មោះបោះឆ្នោតទាំងអស់ ។ ក្នុងបញ្ជីនោះ មានឈ្មោះ មានអាស័យដ្ឋានរស់នៅ និងមុខងាររបស់អ្នកចុះឈ្មោះ ។
យើងគ្រប់គ្នាមានសិទ្ធិមើលក្នុងបញ្ជីនេះ ។ គេបោះពុម្ពបញ្ជីថ្មីរាល់ឆ្នាំ វៀសវាងតែឆ្នាំបោះឆ្នោតសភា ។ ក្នុងឆ្នាំបោះឆ្នោតនោះគេបោះពុម្ពបញ្ជីពីរក្បាល ; មួយក្បាល ទុកសម្រាប់ឱយអ្នករាល់គ្នាពិនិត្យថាតើការចុះឈ្មោះ របស់គេបានត្រឹមត្រូវឬទេ, មួយក្បាលទៀតសម្រាប់ ប្រើប្រាស់ក្នុងពេលគេបោះឆ្នោត ។

## តើខ្ញុំអាចរកមើលបញ្ជីបោះឆ្នោតនៅកន្លែងណា?

គ្រប់ទីស្នាក់ការអ្នកកាន់បញ្ជីបោះឆ្នោតនិងបណ្ណាល័យរដ្ឋមានទុកគ្រប់បញ្ជីបោះឆ្នោតសម្រាប់ប្រជាជនញូ៉ស៊ីឡែន ។ គ្រប់ប៉ុស្តអូសហ្វីសក៏មានចំឡងទុកបញ្ជីសាកលនិងបញ្ជីមោរីតាមតំបន់របស់គេដែរ ។ ប៉ុស្តអូសហ្វីសធំៗជាច្រើន ក៏មានទុកបញ្ជីមណ្ឌលជិតខាងផងដែរ ។

ម្យ៉ាងទៀតអ្នកអាចពិនិត្យបញ្ជី ថាតើដំណឹងអ្នកបានចុះត្រឹមត្រូវឬទេដោយមើលនៅក្នុងវិបសាយរបស់យើង www.elections.org.nz

## តើគេយកដំណឹងចុះឈ្មោះបោះឆ្នោតទៅធ្វើអ្វី?

ពេលអ្នកចុះឈ្មោះ ឈ្មោះអ្នក អាស័យដ្ឋានរស់នៅ និងមុខងាររបស់អ្នក ប៉ុណ្ណោះដែលបង្ហាញនៅលើបញ្ជីបោះពុម្ពរបស់មណ្ឌលបោះឆ្នោតរបស់អ្នក ។ ឯកសារនេះគេបើកចំហរសម្រាប់សាធារណះជនមកពិនិត្យមើល ។ ដំណឹងទាំងនេះព្រមទាំងជួរអាយុរបស់អ្នក អាស័យដ្ឋានផ្ញើឬ អ្នកមានជាប់សាច់ឈាមជាមោរី (បើត្រូវឆ្លើយ), គេអាចផ្តល់ទៅអ្នកស្រាវជ្រាវវិទ្យាសាស្រ្ត អ្នកស្រាវជ្រាវផ្នែកសុខាភិបាល បេក្ខជនឈរឈ្មោះ សមាជិកសភា ឬគណះបក្សនយោបាយ ។ ដំណឹងនេះក៏ផ្តល់ សម្រាប់ការបោះឆ្នោតជ្រើសរើស ក្រុមអាជ្ញាធរតាមតំបន់, ជ្រើសរើសគណះមណ្ឌលផ្នែកសុខាភិបាល ព្រមទាំងផ្តល់សម្រាប់ ធ្វើប្រជាមតិ និង ការស្ទង់មតិ ។ គណះវិនិច្ឆ័យ (Jury ) ក៏ជ្រើសរើសចេញអំពីបញ្ជីបោះឆ្នោតនេះដែរ ។

## ឱយយើងដឹងភ្លាមបើអ្នកមានការកែប្រែអំពីដំណឹងអ្នកក្នុងការចុះឈ្មោះ?

## តើខ្ញុំត្រូវធ្វើដូចម្តេចបើខ្ញុំផ្លាស់ប្តូរអាសយដ្ឋាន?

មុននឹងអ្នកផ្លាស់ប្តូរលំនៅ, អ្នកគ្រាន់តែទៅបំពេញក្រដាសនៅញ៉ូស៊ីឡេនប៉ុស្តអូសហ្វិស" Mail rolls Re-direct Request ក្រដាសសុំប្តូរ ទីសដៅផ្ញើ"នៅកន្លែងគេ ។ គេនឹងចែកសំបុត្រអ្នកទៅអាសយដ្ឋានថ្មី ព្រមទាំងឱយដំណឹង ទៅអ្នកកាន់បញ្ជីបោះឆ្នោតអំពី អាសយដ្ឋានថ្មីរបស់អ្នក ។ បើអាសយដ្ឋានថ្មីនៅមណ្ឌលដដែល អ្នកកាន់បញ្ជីបោះឆ្នោតគ្រាន់តែប្តូរ អាសយដ្ឋានថ្មីក្នុងបញ្ជី ហើយគេផ្ញើសំបុត្រមកអ្នកប្រាប់បញ្ជាក់ថាគេបានប្តូរ ។ បើសិនជាអ្នកផ្លាស់ទៅនៅមណ្ឌលថ្មី គេនឹងផ្ញើក្រដាសបោះពុម្ពចុះឈ្មោះរបស់អ្នក ដើម្បីឱយអ្នកពិនិត្យ, ចុះហត្ថលេខា និងផ្ញើមកគេវិញ ។ អ្នកដែលកាន់បញ្ជីបោះឆ្នោត នៅមណ្ឌលថ្មី ក្រោយពីបានទទួលក្រដាសចុះឈ្មោះអ្នក ដែលចុះហត្ថលេខារួចហើយ គេនឹងចុះឈ្មោះអ្នកក្នុងបញ្ជីថ្មីហើយនឹង ផ្ញើសំបុត្រមកប្រាប់បញ្ជាក់ ។ បើអ្នកកាន់បញ្ជីបោះឆ្នោត មិនឃើញឈ្មោះអ្នកនៅក្នុងបញ្ជីណាមួយទេ គេនឹងផ្ញើ ក្រដាសចុះឈ្មោះមកអាសយដ្ឋានអ្នកថ្មី ។ ម្យ៉ាងទៀត អ្នកអាចបំពេញក្រដាសចុះឈ្មោះថ្មី ឬក៏ចូលមកវិបសាយ របស់យើង www.elections.org.nz ដើម្បីប្តូរ អាសយដ្ឋានថ្មីរបស់អ្នក online តាមប្រព័ន្ធអ៊ិនធឺណិត។

## តើខ្ញុំត្រូវធ្វើដូចម្តេចបើខ្ញុំផ្លាស់ប្តូរឈ្មោះឬប្តូរមុខងារ?

បើអ្នកផ្លាស់ប្តូរឈ្មោះឬប្តូរមុខងារ អ្នកត្រូវសរសេរប្រាប់មកអ្នកកាន់បញ្ជីនៅមណ្ឌលរបស់អ្នកយ៉ាងឆាប់ដែលអាចធ្វើបាន អំពីការផ្លាស់ប្តូរនោះ ។ ម្យ៉ាងទៀត, អ្នកអាចបំពេញ ក្រដាសចុះឈ្មោះថ្មី ឬក៏អាច ផ្លាស់ប្តូរដំណឹងថ្មីរបស់អ្នក តាមរយះវិបសាយរបស់យើង www.elections.org.nz ។

## យ៉ាងដូចម្តេចបើខ្ញុំភ្លេចប្រាប់ពីការផ្លាស់ប្តូរដំណឹងរបស់ខ្ញុំ?

បើអ្នកភ្លេចប្រាប់អំពីការផ្លាស់ប្តូរដំណឹងរបស់អ្នកមកយើង យើងមិនអាចទាក់ទងអ្នកបានឡើយ ពេលគេធ្វើយុទ្ធការចុះឈ្មោះឱយត្រឹមត្រូវ ឈ្មោះអ្នកនឹងត្រូវគេលុបចេញអំពីបញ្ជី ។ អ្នកនឹងត្រូវបំពេញក្រដាសសុំចុះឈ្មោះសារជាថ្មី ។

# យុទ្ធការចុះឈ្មោះឱយបានត្រឹមត្រូវ

## អ្វីជាយុទ្ធការចុះឈ្មោះឱយបានត្រឹមត្រូវ?

រាល់ឆ្នាំប្រជាជនញ៉ូស៊ីឡេនរាប់ពាន់អ្នក តែងតែមានការផ្លាស់ប្តូរជីវិតរស់នៅ ។ គេផ្លាស់ប្តូរផ្ទះ គេរៀបការ គេផ្លាស់ប្តូរមុខងារ ។ ប្រជាជនជាច្រើនវិលត្រឡប់ពីបរទេស។ ជូនកាលអ្នកទាំងនេះមិនបានឱយដំណឹងទៅអ្នកកាន់បញ្ជីបោះឆ្នោត អំពីការផ្លាស់ប្តូរជីវិតរស់នៅ របស់គេឡើយ ។ ហេតុនេះហើយបានជាយើង មានធ្វើយុទ្ធការចុះឈ្មោះឱយបានត្រឹមត្រូវជារឿយៗ ។ ម្នាក់ៗត្រូវតែពិនិត្យ និង បើចាំបាច់ដែលត្រូវការកែប្រែ ដំណឹងចុះឈ្មោះ សូមឱយដំណឹងទៅ អ្នកកាន់បញ្ជីបោះឆ្នោតឱយដឹងដើម្បី គេអាចបញ្ចូលដំណឹង ផ្លាស់ប្តូរនេះទៅ ក្នុងបញ្ជីបោះឆ្នោតថ្មី។

## តើខ្ញុំត្រូវធ្វើដូចម្តេចពេលមានយុទ្ធការចុះឈ្មោះឱយបានត្រឹមត្រូវ?

អ្នកត្រូវពិនិត្យ បើចាំបាច់ ត្រូវធ្វើការកែប្រែដំណឹងចុះឈ្មោះរបស់អ្នក។ អ្នកកាន់បញ្ជីបោះឆ្នោត ផ្ញើក្រដាស ចុះឈ្មោះទៅ គ្រប់គ្នាដល់អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីចាស់។ ក្រដាសកែប្រែចុះឈ្មោះរបស់អ្នកនេះ បង្ហាញ អំពីដំណឹងដែលអ្នកបានចុះ ។ ក្នុងក្រដាសនេះមានកន្លែង សម្រាប់ឱយអ្នកកែប្រែដំណឹង ។ រួចហើយគ្រាន់តែចុះ ហត្ថលេខាដាក់ថ្ងៃខែ លើក្រដាសហើយផ្ញើមកយើងតាម ស្រោមសំបុត្រឆ្លើយតប ដែលផ្ជាប់មកជាមួយស្រាប់ ។ បើឃើញថាដំណឹង អ្នកត្រឹមត្រូវអស់ហើយ អ្នកមិនចាំបាច់ឆ្លើយតបមកយើងទេ ឈ្មោះអ្នក នឹងមាននៅក្នុងបញ្ជី ដែលមានចុះដំណឹងអ្នកដូចបង្ហាញនៅលើ ក្រដាសកែប្រែចុះឈ្មោះរបស់អ្នកដែលបានទទួលនោះ ។

## យ៉ាងដូចម្តេចបើខ្ញុំមិនបានផ្ញើក្រដាសកែប្រែចុះឈ្មោះត្រឡប់ទៅវិញពេលយុទ្ធការចុះឈ្មោះ?

អ្នកនៅមានឈ្មោះក្នុងបញ្ជីដដែល ដំណឹងក្នុងបញ្ជីនោះដូចនឹងដំណឹង បង្ហាញនៅលើក្រដាសកែប្រែចុះឈ្មោះផ្ញើមកអ្នកនោះ ។

## ចុះបើខ្ញុំទទួលក្រដាសកែប្រែចុះឈ្មោះរបស់អ្នកដទៃដែលឈប់រស់នៅអាសយដ្ឋាននេះហើយនោះ?

អ្នកគួរផ្ញើបន្តទៅអាសយដ្ឋានថ្មីរបស់អ្នកនោះ ឬបើអ្នកមិនដឹងអាសយដ្ឋានថ្មីនោះទេ អ្នកសរសេរលើស្រោមសុំបុត្រថា “Gone no address” ហើយដាក់ផ្ញើត្រឡប់តាមប៉ុស្តមកវិញ ។ សុំបុត្រនេះនឹងផ្ញើត្រឡប់ទៅអ្នកកាន់បញ្ជីបោះឆ្នោតវិញ ហើយគេនឹងលុបឈ្មោះអ្នកនោះចេញអំពីបញ្ជីបោះឆ្នោត ។

## ចុះបើខ្ញុំមិនបានទទួលក្រដាសកែប្រែចុះឈ្មោះនោះ?

អ្នកត្រូវបំពេញក្រដាសចុះឈ្មោះថ្មី ។ ពេលណាអ្នកកាន់បញ្ជីទទួលបាន ក្រដាសចុះឈ្មោះថ្មីរបស់អ្នកដែលបំពេញសព្វគ្រប់ហើយនោះ អ្នកនិងមានឈ្មោះចុះនៅក្នុងបញ្ជី ។

# ព្រំដែនមណ្ឌលបោះឆ្នោត

## ខ្ញុំមិនដែលផ្លាស់ផ្ទះផង ហេតុអ្វីបានជាគេដាក់ខ្ញុំនៅមណ្ឌលបោះឆ្នោតផ្សេងទៀត?

ក្នុងមណ្ឌលបោះឆ្នោតនិមួយៗមានចំនួនប្រជាជនសឹងប្រហែលគ្នា ។ តែមណ្ឌលខ្លះអាចរីកចំនួន មណ្ឌលខ្លះទៀតអាចថយចំនួន ហើយព្រំដែនមណ្ឌលបោះឆ្នោតក៏ត្រូវកែតម្រូវដែរ ។ ប្រាំឆ្នាំម្តង ក្រោយពីគេធ្វើការស្រង់ចំនួនប្រជាជន គេពិនិត្យមើលព្រំដែន នៅគ្រប់មណ្ឌលបោះឆ្នោត

ឡើងវិញ។ បើសិនជាមានប្រជាជនច្រើនផ្លាស់ប្តូរកន្លែងរស់នៅ ព្រំដែនមណ្ឌលបោះឆ្នោតមួយៗត្រូវតែកែតម្រូវ ដើម្បីឱយមានចំនួនប្រជាជនប្រហាក់ប្រហែលគ្នា ។ ព្រំដែនថ្មីនេះ គេយកមកប្រើក្នុងពេលបោះឆ្នោត លើកក្រោយ ។

## ការបោះឆ្នោតដ៏ទៃទៀត

### អ្វីជាការបោះឆ្នោតសភាពិសេស?

ជួនកាលកៅអីសភាក្នុងមណ្ឌលខ្លះនៅទំនេរក្នុងចន្លោះពេលបោះឆ្នោតសាកល ។ អ្នកដែលនៅមណ្ឌលនោះ មានឱកាស បោះឆ្នោតជ្រើសរើសរកសមាជិកសភាថ្មី ។ ការបោះឆ្នោតនេះហៅថា ការបោះឆ្នោតសភាពិសេស ។ គេនឹងយកបញ្ជីកែប្រែថ្មី យកមកប្រើសម្រាប់ការបោះឆ្នោតពិសេសនៅមណ្ឌលនេះ ។

### អ្វីជាការបោះឆ្នោតតាមតំបន់?

ពេលអ្នកចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតសភា ជាស្វ័យប្រវត្តិ អ្នកក៏ចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតអាជ្ញាធរតាមតំបន់ដែរ ។ បានន័យថាអ្នកអាចបោះឆ្នោតជ្រើសរើសក្រុមអាជ្ញាធរតាមតំបន់ និងគណះមណ្ឌលផ្នែកសុខាភិបាល ដែលរួមបញ្ចូលការបោះឆ្នោតជ្រើសរើស ចៅហ្វាយ សំរាប់ក្រុងឬស្រុក និង ការជ្រើសរើសសមាជិកតំណាងរបស់អ្នកនៅតាមភូមិភាគ, តាមសាលាក្រុងឬ ស្រុក ជ្រើសរើសគណះសហគមន៏ គណះមណ្ឌលផ្នែកសុខាភិបាល និងគណះផ្សេងៗទៀត ដូចជាក្រុមអ្នកអនុញ្ញាតប័ត្រ ជាដើម ។

### តើខ្ញុំមានសិទ្ធិបោះឆ្នោតប្រជាមតិផ្តើមដោយប្រជាពលរដ្ឋ និង/ឬ ប្រជាមតិផ្តើមដោយរដ្ឋាភិបាលឬទេ?

ពេលអ្នកបានចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតសភាហើយ ជាស្វ័យប្រវត្តិ អ្នកក៏ចុះឈ្មោះបោះឆ្នោតប្រជាមតិ ផ្តើមដោយប្រជាពលរដ្ឋ និង/ឬ ដោយរដ្ឋាភិបាលដែរ ។

## ដំណឹងបន្ថែម

### តើខ្ញុំអាចបានដំណឹងនេះជាភាសាផ្សេងទៀតឬទេ?

បើអ្នកចង់បានកូនសៀវភៅនេះជាភាសារ មៅរី, ឃុកអាយឡិន, ថុងង៉ា, សាមន, ចិន, ឬកូរេ គ្រាន់តែទូរសព្ទ ដោយឥតគិតថ្លៃ មកលេខ
0800 ENROL NOW, (0800 36 76 56)
យើងនឹងផ្ញើទៅឱយអ្នក មួយក្បាលភ្លាម ។

អគុណអ្នកដែលបានអានឯកសារនេះ ។ បើអ្នកត្រូវការគេជួយបន្ថែម សូមទូរសព្ទដោយឥតគិតថ្លៃ មកយើងលេខ
0800 ENROL NOW, (0800 36 76 56)
ឬមកមើលវិបសាយ www.elections.org.nz ។

យើងសង្ឃឹមថាយើងបានឆ្លើយនូវសំនួររបស់អ្នក អំពីការចុះឈ្មោះបោះឆ្នោតសព្វគ្រប់អស់ហើយ ។


Electoral Enrolment Centre
New Zealand Post Limited
PO Box 190
Wellington 6015

| | |
|---|---|
| Phone : | 0800 ENROL NOW<br>(0800 36 76 56) |
| Fax : | (04) 801 0709 |
| Email : | enrol@elections.org.nz |
| Website : | www.elections.org.nz<br>Or visit www.elections.org.nz |